# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០៣៥/២២ .......... អអរ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តតាកែវ "

ព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តតាកែវ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម យស ណារ៉ុ ប្រធានក្រុមប្រឹក្សាខេត្តតាកែវ**
- **លោក ស្រី សាម មេឃុំស្រែរនោង ស្រុកត្រាំកក់**
- **លោក គុប ប៊ុនថន មេឃុំអង្គតាសោម ស្រុកត្រាំកក់**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

## I. សេចក្តីផ្តើម

ខេត្តតាកែវ មានផ្ទៃដីសរុបចំនួន ៣.៧៥៤,៤៣គ.ម$^{២}$ ចែកចេញ ៩ស្រុក ១ក្រុង និង ៩៧ឃុំ ៣សង្កាត់ ១.១២១ភូមិ មានប្រជាពលរដ្ឋរស់នៅសរុបចំនួន ១.០៤២.១២៤នាក់ ស្រី ៥៣៥.៦៩៩នាក់ ក្នុងនោះអាយុ១៨ឆ្នាំឡើងមានចំនួន ៦៧១.៨៨៨នាក់ ស្រី ៣៤៨.៩៣៩នាក់ ស្មើនឹង ២២៧.៧១៧គ្រួសារ ដែលសក្តានុពលសេដ្ឋកិច្ចរបស់ខេត្តពឹងផ្អែកលើវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងនេសាទជាលក្ខណៈគ្រួសារ ព្រមទាំងប្រកបអាជីវកម្មផ្សេងៗទៀត។

## II. វឌ្ឍនភាពការងារ

### ❖ ក្រុមប្រឹក្សាខេត្ត

- ថ្នាក់ដឹកនាំខេត្តតាកែវ មានចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ធ្វើឱ្យប្រជាពលរដ្ឋរស់នៅបានសុខសាន្ត និងមានជីវភាពធូរធារ ក្នុងនោះកិច្ចការសំខាន់ៗ ដូចជា ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងការដឹកនាំ ការអនុវត្តតួនាទី ភារកិច្ច ស្របតាមជំនាញ និងបទពិសោធន៍ ការផ្លាស់ប្តូរទស្សនៈ ឥរិយាបថរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៅក្រោមឱវាទ ដែលឈានទៅរកការផ្តល់សេវា ប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍប្រកបដោយសមធម៌ និងចីរភាព។
- ក្រុមប្រឹក្សាខេត្តមានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស, គណៈកម្មាធិការលទ្ធកម្ម, គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ, គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស និងគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។
- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្តនៅថ្នាក់ក្រុង ស្រុកទាំង ១០ ដើម្បីទទួលយកសំណើ សំណូមពររបស់ប្រជាពលរដ្ឋ មកពិភាក្សា និងឆ្លើយតប។
- បានចូលរួមផ្សព្វផ្សាយ អប់រំណែនាំប្រជាពលរដ្ឋនៅមូលដ្ឋានតាម សារអប់រំណែនាំរបស់ក្រសួងសុខាភិបាលជាប្រចាំ ព្រមទាំងបានឧបត្ថម្ភថវិកា គ្រឿងឧបភោគ បរិភោគដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជំងឺនេះទូទាំងខេត្ត។
- បានត្រួតពិនិត្យដំណើរការឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋក្រីក្រ ស្ត្រីមានផ្ទៃពោះ និងកុមារនៅគ្រប់មូលដ្ឋាន តាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់។
- បានត្រួតពិនិត្យការផ្តល់សេវាជូនប្រជាពលរដ្ឋនៅអង្គភាពច្រកចេញ-ចូលតែមួយរដ្ឋបាលខេត្ត និងនៅការិយាល័យច្រកចេញ ចូលតែមួយ រដ្ឋបាលក្រុង រដ្ឋបាលស្រុក។

### ❖ ឃុំស្រែរនោង និងឃុំអង្គតាសោម ស្រុកត្រាំកក់

វឌ្ឍនភាពសំខាន់ៗ ដែលក្រុមប្រឹក្សាឃុំសម្រេចបានរួមមាន៖

- បានអនុវត្តនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព, រៀបចំសណ្តាប់ធ្នាប់, ការពារសន្តិសុខជូនប្រជាពលរដ្ឋ និងមានការដោះស្រាយ សម្របសម្រួលបណ្តឹងជូនប្រជាពលរដ្ឋ។
- បានបង្ក្រាបបទល្មើស ដូចជា ល្បែងស៊ីសង គ្រឿងញៀន អំពើលួចឆក់ប្លន់ គ្រោះថ្នាក់ចរាចរ។

- បានរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងឃុំរួមមាន ជួសជុលផ្លូវក្រាលគ្រួស ដាក់លូតាមដងផ្លូវ និង ប្រឡាយទឹក ជីកអណ្តូងទឹកស្អាត ជីកស្រះសហគមន៍ ព្រមទាំងបង្កើតឱ្យមានស្ថានីយទឹកបរិសុទ្ធ ដើម្បីតម្រូវការរបស់ប្រជាពលរដ្ឋ។
- បានឧបត្ថម្ភដល់គ្រួសារក្រីក្រ ស្ត្រីមានផ្ទៃពោះ កុមារ ចាស់ជរា និងបានចុះផ្សព្វផ្សាយអំពីសុខភាពអនាម័យជូនប្រជាពលរដ្ឋ។
- បានចុះផ្សព្វផ្សាយអំពីការណែនាំរបស់រាជរដ្ឋាភិបាល សារអប់រំសុខភាពរបស់ក្រសួងសុខាភិបាល ក្នុងការប្រឆាំងនឹងជំងឺកូវីដ-១៩ ព្រមទាំងបានចែកម៉ាស់ជូនប្រជាពលរដ្ឋ។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានដាក់ចេញនូវទិសដៅការងារចាំបាច់មួយចំនួនដូច ខាងក្រោម៖

- ផ្តល់យោបល់ និងកំណត់ទិសដៅខេត្តក្នុងការពង្រីកថាមពលអគ្គីសនី និងទឹកស្អាត។
- ជំរុញការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំដើម្បីធានាបាននូវការគ្រប់គ្រងប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ចូលរួមទប់ស្កាត់បញ្ហាទំនាស់ដីធ្លី។
- ជំរុញការផ្តល់សេវាសាធារណៈ និងសេវារដ្ឋបាលជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា តាមរយៈការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម និងយន្តការច្រកចេញចូលតែមួយ ដើម្បីបង្ខិតសេវាសាធារណៈឱ្យកៀកនឹងប្រជាពលរដ្ឋមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។
- បន្តការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព
- បន្តការគាំទ្រយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
- បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍ និងការកសាងកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ឱ្យមានសង្គតិភាព និងការរៀបចំយុទ្ធសាស្ត្រថវិកា ឱ្យសមស្របទៅតាមតម្រូវការក្នុងការអភិវឌ្ឍ។
- បន្តចូលរួមក្នុងការប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ចូលរួមផ្សព្វផ្សាយអប់រំណែនាំ ប្រជាពលរដ្ឋនៅមូលដ្ឋានតាមសារអប់រំណែនាំរបស់ក្រសួងសុខាភិបាល។

### ❖ ឃុំស្រែនោង ស្រុកត្រាំកក់

- បន្តជួសជុល និងកសាងហេដ្ឋារចនាសម្ព័ន្ធតាមបណ្តាភូមិ

- បន្តជំរុញប្រជាពលរដ្ឋឱ្យខិតខំពង្រីកផ្ទៃដីដាំដុះ និងមុខរបរផ្សេងៗ
- បន្តការខិតខំពង្រឹងការអនុវត្តគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព និងពង្រឹងសុខសណ្តាប់ធ្នាប់សាធារណៈ និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ
- បន្តអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋក្រីក្រ
- ខិតខំគៀងគរអង្គការដៃគូ អ្នកវិនិយោគ និងសប្បុរសជនជិតឆ្ងាយ ដើម្បីចូលរួមអភិវឌ្ឍន៍ភូមិឃុំឱ្យមានភាពរីកចម្រើន។
- បន្តចូលរួមសកម្មភាពនានាក្នុងការប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសបន្តអប់រំ និងណែនាំដល់ប្រជាពលរដ្ឋឱ្យអនុវត្តវិធានការ ៣កុំ និង ៣ការពារ។

## IV. សម្គាល់

នៅក្នុងសន្និសីទសារព័ត៌មាននេះ ទទួលបានសំណួរពីអ្នកសារព័ត៌មាន និងការពន្យល់បកស្រាយពីវាគ្មិនដូចខាងក្រោម៖

១. តើតំបន់ទេសចរណ៍នៅក្នុងខេត្តតាកែវមានអ្វីខ្លះ?

- នៅក្នុងខេត្តតាកែវ មានតំបន់ទេសចរណ៍សំខាន់ៗដូចជា៖ រមណីយដ្ឋានទន្លេបាទី, រមណីយដ្ឋានភ្នំដា, រមណីយដ្ឋានភ្នំជីសូ, រមណីយដ្ឋានភ្នំតាម៉ៅ, រមណីយដ្ឋានភ្នំខ្លែង, រមណីយដ្ឋានភ្នំជីតាពេជ្រ, រមណីយដ្ឋានជ្រោះផ្គោក, រមណីយដ្ឋានកំពូលពេជ្រ, រមណីយដ្ឋានត្រីមាស, រមណីយដ្ឋានភ្នំពុទ្ធគិរី។

២. តើប្រជាពលរដ្ឋដែលចំណាកស្រុកក្នុងខេត្តតាកែវមានការថយចុះយ៉ាងដូចម្តេច?

- បច្ចុប្បន្ននេះ ចំនួនប្រជាជនសំណាកស្រុកនៅក្នុងខេត្តតាកែវមានការថយចុះគួរឱ្យកត់សម្គាល់ដែលមានចំនួនប្រមាណ៧០,០០០នាក់ ដោយសារតែការមានការរីកចម្រើនច្រើនផ្នែកវិស័យកសិកម្ម។ ជាក់ស្តែងក្នុងឆ្នាំនេះ ការនាំចេញផលស្រូវមានប្រមាណជាង ១លានតោន មានការកើនឡើងបើធៀបនឹងឆ្នាំ២០២០ មានត្រឹមតែជាង១៦ម៉ឺនតោន។

ថ្ងៃសុក្រ ៤រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២